# មេរោគកូរ៉ូណា (កូវីដ-19) នៅក្នុងទីក្រុងឡូវែល

មេរោគកូរ៉ូណា ឬ កូវីដ-19 គឺជាវីរុសផ្លូវដង្ហើមមួយ ដែលជាទូទៅឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត នៅពេលដែលអ្នកដែលផ្ទុកវីរុសនេះ ក្អក ឬកណ្តាស់ ដែលការឆ្លងនេះស្រដៀងនឹងជំងឺផ្តាសាយ ឬជំងឺផ្លូវដង្ហើមដទៃទៀត។ ករណីដំបូងនៃអ្នកមានជំងឺកូវីដ-19 នៅក្នុងរដ្ឋម៉ាសាឈូសេតត្រូវបានគេរាយការណ៍នៅថ្ងៃទី 01 ខែកុម្ភៈ ឆ្នាំ 2020។ ចំនួនករណីអ្នកកើតជំងឺនេះនៅរដ្ឋម៉ាសាឈូសេតបានចាប់ផ្តើមកើនឡើងយ៉ាងឆាប់រហ័ស នៅដើមខែមិនា ហើយករណីដំបូងនៅឡូវែលត្រូវបានគេរាយការណ៍នៅថ្ងៃទី15 ខែមិនា ឆ្នាំ2020 ។

ដឹកនាំដោយ នាយកដ្ឋានសុខភាព (Health Department) និងក្រុមការងារសង្គ្រោះបន្ទាន់ (Emergency Management) ទីក្រុងឡូវែលបានអនុវត្តការឆ្លើយតបយ៉ាងម៉ត់ចត់ និងធ្វើការត្រៀមខ្លួនរួចរាល់ ចាប់តាំងពីការចាប់ផ្តើមដំបូងនៃជំងឺកូរ៉ូណានេះ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះអាចប្រព្រឹត្តិទៅបាន ដោយមានការសម្របសម្រួលជាមួយភ្នាក់ងារថ្នាក់រដ្ឋ និងដៃគូសុខភាពក្នុងតំបន់ រួមមានមន្ទីរពេទ្យ Lowell General Hospital, Trinity EMS, និង Lowell Community Health Center ហើយកិច្ចខិតខំប្រឹងប្រែងនេះបានធ្វើអោយហេដ្ឋារចនាសម្ព័ន្ធសុខភាពក្នុងសហគមន៍កាន់តែប្រសើរឡើង ដូចជាបង្កើនការធ្វើតេស្ត និងចំនួនគ្រែមន្ទីរពេទ្យ។

## រោគសញ្ញា

រោគសញ្ញារបស់មេរោគកូរ៉ូណាអាចបង្ហាញឡើងក្នុងរយៈពេល2 ទៅ14ថ្ងៃ ក្រោយប៉ះពាល់នឹងមេរោគ ដែលរោគសញ្ញារួមមាន៖ គ្រុនក្តៅ ក្អក ដង្ហើមខ្លី ពិបាកដកដង្ហើម ឈឺបំពង់ក ឈឺក្បាល ឈឺសាច់ដុំ មានអារម្មណ៍រងារ ញ័រញាក់ និងការបាត់បង់រសជាតិ ឬក្លិន ។ ភាពធ្ងន់ធ្ងរនៃរោគសញ្ញាទាំងនេះមានមានភាពខុសគ្នាទៅតាមអ្នកជំងឺនិមួយៗ។ អ្នករស់នៅរដ្ឋម៉ាសាឈូសេតដែលមានរោគសញ្ញាកូវីដខាងលើ អាចធ្វើឲ្យប្រាកដថាតើអ្នកត្រូវការធ្វើតេស្ត និងការយកចិត្តទុកដាក់ពីមន្ទីរពេទ្យឬអត់ ដោយគ្រាន់តែប្រើឧបករណ៍អនឡាញតាមរយៈ Buoy Health ដែលអាចចូលបានតាមរយៈ៖ buoyhealth.com/mass ។ ប្រព័ន្ធនេះមិនត្រូវបានណែនាំឲ្យប្រើប្រាស់ក្នុងស្ថានភាពអាសន្ននោះទេ ហើយក៏មិនអាចជំនួសដំបូន្មានវេជ្ជសាស្ត្រ និងការធ្វើរោគវិនិច្ឆ័យរបស់អ្នកជំនាញបានឡើយ។

## ការធ្វើតេស្ត

នៅថ្ងៃទី 7 ខែមេសា CVS Health បានបើកដំណើរការកន្លែងធ្វើតេស្តរហ័សមួយនៅទីក្រុងឡូវែល ដែលមានទីតាំងស្ថិតនៅចំណតឡាននៃរោងភាពយន្ត Showcase Cinema ។ កន្លែងធ្វើតេស្តនេះអនុញ្ញាតឱ្យបើកឡានឆ្លងកាត់តែប៉ុណ្ណោះ និងផ្តល់លទ្ធផលភ្លាមៗនៅនឹងកន្លែងសម្រាប់អ្នកជំងឺក្នុងរយៈពេលប្រហែល 15 នាទីប៉ុណ្ណោះ។ កន្លែងធ្វើតេស្តនេះបើកដំណើរការពីម៉ោង 9ព្រឹកដល់5ល្ងាច សំរាប់ថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ម៉ោង10ព្រឹក ដល់4ល្ងាចសំរាប់ថ្ងៃសៅរ៍ និង 10ព្រឹក ដល់3ល្ងាច សំរាប់ថ្ងៃអាទិត្យ។ បុគ្គលដែលចង់ធ្វើតេស្តត្រូវតម្រូវអោយចុះឈ្មោះជាមុននៅលើគេហទំព័ររបស់ CVS Minute Clinic បើមិនដូច្នោះទេ ចំពោះបុគ្គលណាដែលកំពុងបង្ហាញរោគសញ្ញា ហើយជឿជាក់ថាពួកគេត្រូវការធ្វើតេស្ត គួរតែទាក់ទងគ្រូពេទ្យប្រចាំខ្លួន (primary care physician - PC) របស់ពួកគេដែលនឹងធ្វើការវាយតម្លៃ និងចេញបញ្ជារឲ្យមានការធ្វើតេស្តសម្រាប់បុគ្គលនោះក្នុងករណីសមស្រប។ បុគ្គលដែលមិនមានគ្រូពេទ្យប្រចាំខ្លួន (PCP) អាចទាក់ទង Lowell Community Health Center (មជ្ឈមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែល)ដែលបានបង្កើតប្រព័ន្ធមួយដើម្បីពិនិត្យអ្នកជំងឺ និងកំណត់ថាតើបុគ្គលនោះចាំបាច់ត្រូវការធ្វើតេស្តឬអត់។ អ្នករាល់គ្នាដែលបង្ហាញរោគសញ្ញានៃមេរោគកូរ៉ូណា គួរតែនៅដាច់ដោយឡែកពីគេរហូតដល់ដំណើរការធ្វើតេស្តនេះចប់សព្វគ្រប់ ហើយមិនគួរចាកចេញពីផ្ទះរបស់ពួកគេរហូតដល់ការធ្វើតេស្តបង្ហាញលទ្ធផលអវិជ្ជមាន។

## ការត្រួតពិនិត្យករណី និងការតាមដានរកអ្នកដែលប៉ះពាល់ជាមួយអ្នកជំងឺ

មន្ទីរសុខាភិបាលក្រុងទទួលបានពត៌មានសំខាន់ៗ ពីអ្នករស់នៅទីក្រុងឡូវែលទាំងអស់ ដែលធ្វើតេស្តវិជ្ជមានCOVID-19។ គិលានុបដ្ឋាយិកាសុខភាពសាធារណៈទំនាក់ទំនងផ្ទាល់ទៅអ្នកជំងឺនីមួយៗ ដើម្បីប្រាប់ពួកគេពីតម្រូវការនៃការរស់នៅដាច់ដោយឡែកមួយរយៈ និងតាមដានរកមនុស្សទាំងឡាយណាដែលពួកគេបានប៉ះពាល់ជាមួយ។ តាមរយៈដំណើរការមួយដែលគេស្គាល់ថាជាការតាមដានរកអ្នកដែលប៉ះពាល់ជាមួយអ្នកជំងឺ ( Contact Tracing) បុគ្គលិកនាយកដ្ឋានធ្វើការទំនាក់ទំនងជាមួយអ្នកទាំងអស់ដែលបានរកឃើញថាបានប៉ះពាល់ផ្ទាល់ជាមួយអ្នកជំងឺ និងណែនាំពួកគេអំពីវិធានការដែលត្រូវធ្វើតាម ដោយសារការប៉ះពាល់របស់ពួកគេនឹងវីរុស។ កិច្ចខិតខំប្រឹងប្រែងទាំងនេះត្រូវបានគាំទ្របន្ថែម ដោយកិច្ចសហការណ៍រវាងរដ្ឋបាលលោក Baker និងអង្គការ Partner in Health កាលពីពេលថ្មីៗនេះ។ ការតាមដានរកអ្នកដែលប៉ះពាល់ជាមួយអ្នកជំងឺ មានមុខងារសុខភាពសាធារណៈដ៏សំខាន់មួយ ក្នុងការគ្រប់គ្រងការរីករាលដាលនៃវីរុសនេះ។ វាសំខាន់ណាស់ដែលប្រជាជនទាំងអស់ការចូលរួមសហការយ៉ាងពេញលេញ នៅដែលគិលានុបដ្ឋាយិកាសុខភាពសាធារណៈទំនាក់ទំនងទៅ។

## បទបញ្ជាកាត់បន្ថយគ្រោះហានិភ័យទូទាំងរដ្ឋ

លោកអភិបាល Baker បានប្រកាសដាក់រដ្ឋម៉ាសាឈូសេតក្នុងភាពអាសន្ន នៅថ្ងៃទី10 ខែមីនា ឆ្នាំ2020 ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលក្នុងការឆ្លើយតបទៅនឹងវីរុសកូរ៉ូណា។ នៅថ្ងៃទី15 ខែមិនា លោកអភិបាល Baker បានបញ្ជាឱ្យបិទសាលារដ្ឋ និងឯកជនទាំងអស់នៅរដ្ឋម៉ាសាឈូសេត ដែលត្រូវបន្តរហូតដល់ចប់ឆ្នាំសិក្សានេះ។ បទបញ្ជានេះក៏រាប់បញ្ចូលកន្លែងថែទាំកុមារ ដែលតម្រូវឱ្យបន្តបិទរហូតដល់ថ្ងៃទី29 ខែមិថុនា ឆ្នាំ2020។ លោកអភិបាល Baker ក៏បានបញ្ជាឱ្យបិទអាជីវកម្មមិនសំខាន់(Non-Essential)ទាំងអស់ ចាប់ពីថ្ងៃទី ២៤ ខែមិនា។ រដ្ឋបាលបានចេញផ្សាយបញ្ជីអាជីវកម្ម និងអង្គការដែលត្រូវបានចាត់ទុកថាជាសេវាកម្មចាំបាច់(Essential Services) និងអាចបន្តដំណើរការក្នុងពេលមានវិបត្តិនេះ។

## ប្រតិបត្តិការនៃសាលាក្រុង

ដើម្បីជួយកាត់បន្ថយការរីករាលដាលនៃ COVID-19 និងដើម្បីការពារសុខភាព និងសុវត្ថិភាពបុគ្គលិកទីក្រុងឡូវែល, សាលាក្រុង ក៏ដូចជាអគារក្រុងទាំងអស់ត្រូវបានបិទជាសាធារណៈចាប់តាំងពីថ្ងៃទី16 ខែមិនា ឆ្នាំ2020 ហើយនឹងបន្តបិទរហូតដល់មានសេចក្តីជូនដំណឹងបន្ថែម។ នេះរួមមាន បណ្ណាល័យ Pollard Memorial Library។ បុគ្គលិកទីក្រុងឡូវែលចាំបាច់មួយចំនួននៅតែបំពេញការងាររបស់ពួកគេ ហើយបុគ្គលិកមិនចាំបាច់ ( Non-Essential Employees) ត្រូវតម្រូវឲ្យធ្វើការពីផ្ទះ។ ប្រជាជន និងបុគ្គលណាដែលត្រូវការសេវាកម្ម ឬការចូលរួមពីទីក្រុង អាចទទួលបានសេវាកម្មពីចម្ងាយតាមអ៊ីនធឺណេត, តាមទូរស័ព្ទ, ឬតាមការផ្ញើសំបុត្រ។ ទូរស័ព្ទទៅ 978-674-4400 សំរាប់ព័ត៌មានបន្ថែម។

## ទីកន្លែងសាធារណៈនៅក្នុងទីក្រុងឡូវែល

កន្លែងក្មេងលេងសាធារណៈទាំងអស់ត្រូវបិទជាសាធារណៈ។ កន្លែងលេងល្បែងកំសាន្តនានានៅក្នុងឧទ្យានសាធារណៈត្រូវបិទ ដែលក្នុងនោះរួមមាន៖ តារាងបាល់បោះ តារាងវាយថេនីស និងតារាងបាល់ទះ។ សួនឧទ្យានទាំងឡាយបន្តបើកបានសម្រាប់តែការប្រើប្រាស់ដែលមិនបង្កឲ្យមានភាពកកកុញ ឬជួបជុំគ្នាច្រើន ដូចជាការរត់ និងការដើរហាត់ប្រាណ ជាដើម។ នាយកដ្ឋានអភិរក្ស និងលំហែកំសាន្តថ្នាក់រដ្ឋ The State Department of Conservation and Recreation បានបិទចំណតឡានសាធារណៈនៅ Lowell Heritage State Park ។

## ការពារខ្លួនអ្នក និងជួយបញ្ឈប់ការឆ្លងរាលដាល

វិធីដែលមានប្រសិទ្ធភាពបំផុតដើម្បីរក្សាសុវត្ថិភាពក្នុងពេលមានជំងឺរាតត្បាតផ្លូវដង្ហើមនេះ គឺត្រូវកាត់បន្ថយឱកាសដែលប៉ះពាល់ដោយផ្ទាល់ ឬប្រយោលជាមួយនឹងជំងឺនេះ។ នោះមានន័យថា ត្រូវនៅផ្ទះគ្រប់ពេល ហើយកាត់បន្ថយទំនាក់ទំនងផ្ទាល់ជាមួយបុគ្គលដទៃក្រៅពីក្រុមគ្រួសារអ្នក។ អនុសាសន៍ផ្សេងទៀតពី CDC និងអាជ្ញាធរសុខាភិបាលនានារួមមាន៖

- លាងដៃរបស់អ្នកឲ្យបានញឹកញាប់ជាមួយសាប៊ូ និងទឹកយ៉ាងហោចណាស់២០វិនាទី
- នៅពេលដែលមិនមានសាប៊ូ និងទឹក អ្នកអាចជំនួសដោយការប្រើទឹកដែលសំលាប់មេរោគ ដែលមានជាតិអាល់កុលយ៉ាងហោចណាស់ 60%
- ជៀសវាងប៉ះពាល់ភ្នែក ច្រមុះ និងមាត់របស់អ្នកជាមួយដៃដែលមិនបានលាងសម្អាត
- ពាក់ម៉ាស ឬរបាំងគ្របមុខ នៅពេលចេញទៅក្រៅផ្ទះ
- សម្អាត និងសម្លាប់មេរោគរាល់វត្ថុ និងផ្ទៃនានា ដែលប៉ះពាល់ញឹកញាប់
- ជៀសវាងទំនាក់ទំនងផ្ទាល់ជាមួយអ្នកដែលឈឺ
- ត្រូវនៅផ្ទះ ប្រសិនបើអ្នកឈឺ

## ព័ត៌មានបន្ថែម

ពលរដ្ឋទាំងអស់ដែលមានសំនួរ ឬការព្រួយបារម្ភទាក់ទងនឹងជំងឺផ្លូវដង្ហើមនេះ ត្រូវលើកទឹកចិត្តឲ្យទំនាក់ទំនងទៅកាន់មណ្ឌលប្រតិបត្តិការសង្គ្រោះបន្ទាន់ នៃទីក្រុងឡូវែល (The city of Lowell's Emergency Operation Center) ផ្ទាល់តាមរយៈលេខទូរស័ព្ទ 978-674-4052 ដែលមានបុគ្គលិកប្រចាំការពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ម៉ោង 8:30 ព្រឹកដល់ 4:30 ល្ងាច ឬទំនាក់ទំនងទៅលេខ 2-1-1 ដែលជាខ្សែទូរស័ព្ទថ្នាក់រដ្ឋ។ អ្នករស់នៅក្នុងរដ្ឋម៉ាសាឈូសេតទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យចុះឈ្មោះដើម្បីទទួលបានព័ត៌មានទាន់ហេតុការណ៍ពីថ្នាក់រដ្ឋដោយផ្ញើពាក្យ COVIDMA ទៅលេខ 888-777 ។

សំរាប់ព័ត៌មានកូវីដ19 ជាភាសាខ្មែរ សូមចូលទៅកាន់៖ https://www.cmaalowell.org/wp/covid-19-resources/